
ទឹកខ្មៅញើស
ការផ្សាយរបស់អ្នកនិពន្ធ

១៥

# ដីកាឿងចៅចិត្រ

បទប្រាំពីរព្យាង្គ

នឹករឿងចៅចិត្រ គិតចងចាំ
និទានយូរឆ្នាំ ល្បីរញ្ជួយ
ចៅចិត្រតស៊ូ តែខ្លួនមួយ
ចាត់ចែងលើកស្ទួយ ត្រួយជីវី។

ជីវិតកម្មករ ក្រជីកត្បូង
បេះដូងស្មោះត្រង់ តួនាទី
ស្មោះទាំងតូចតន់ យុននារី
ទាំងពីររូបកាយ ក្លាយគូស្នេហ៍។

កុលាបប៉ៃលិន ក្លិនក្រអូប
សុសសាយក្រសោប ឱបដីខ្មែរ
ចៅចិត្តជឿជាក់ ស្មោះស្ម័គ្រថៃ
ក្លាយជាចៅកែ ម្ចាស់រ៉ែត្បូង...

៧ មេសា ២០១៥

៤៨

## ពូចាកចេញទៅ...

បទប្រាំពីរព្យាង្គ

អត្ថបទកាព្យផ្ញើទៅបណ្ឌិត កែម ឡី

ពូចាកចេញទៅ នៅកេរ្តិ៍ឈ្មោះ
ក្រអូបពីរោះ ល្បីសុសសាយ
បងប្អូនញាតិមិត្ត ទាំងជិតឆ្ងាយ
ខ្សឹកខ្សួលសោកស្តាយ ស្រណោះពូ។

ពូចាកចេញទៅ នៅប្រវត្តិ
ក្លាហានអំណត់ ហត់តស៊ូ
ឧត្តមគតិ ជនគំរូ
វីរភាពពូ ខ្មែរមិនភ្លេច។

ពូចាកចេញទៅ សូមបានសុខ
ថ្ងៃមុខមានឈ្មោះ រស់ជានិច្ច
រស់ជាបណ្ឌិត ពិតដូចពេជ្រ
មិនគេចក្បត់ជាតិ មាតុភូមិ...។

១១ កក្កដា ២០១៦

ស៊ូ ខេមរិន្ទ - ៨៧

## ៦០

# អ្នកនិពន្ធ សុទ្ធ ប៉ូលីន

### បទប្រាំពីរព្យាង្គ

កវីជើងចាស់ ណាស់ល្បាញល្បី
"ជីវិតឥតន័យ" ស្នាដៃឯក
"រតនា សារ៉ាក់" ដាក់ដោយឡែក
វណ្ណៈបែងចែក បែកអភ័ព្វ ។

កវីតែមួយ ត្រួយដួងចិត្ត
ពាក្យពេចន៍គំនិត ពិតល្អគាប់
បាយកក បកហៅ"គុយទាវគ្រាប់"
ដក់ចិត្តជិតជាប់ ដួងអារម្មណ៍។

គ្រប់ស្នាដៃអ៊ំ ខ្ញុំបានយល់
យោបល់កប់នៅ ជ្រៅឧត្តម
ទស្សនវិជ្ជា ឃ្លាផ្សែផ្សំ
សក្តិសមកវី ល្បីចំណាន។

អត្ថបទវិភាគ ពាក្យជ្រៅជ្រះ
ខ្លឹមសារល្អណាស់ ច្បាស់ដើមដាន
ចុងក្រោយព្រាត់កាយ ឆ្ងាយទាំងប្រាណ
នៅស្រុកមិនបាន ខានជួបជុំ។

ឃ្លាតដីបឹងស្នោ ខោក្រៅក្នុង
*ប៉ុទីហុងកុង ក្រុងផ្លូវលំ
ឃ្លាតកំពង់ចាម ស្នាមមាតុភូមិ
ទ្រនំពីក្មេង ធ្លាប់លេងរត់។

ពីដីស្ទឹងសែន ដែនទឹកខ្មៅ
ហែកមេឃផ្ញើទៅ នាយសមុទ្រ
គោរពស្រឡាញ់ អ៊ំបំផុត
សុខភាពកំណត់ អាយុវែង...

១០ កុម្ភៈ ២០១៦

* ប៉ុទី (បារាំង): តូច